# សុន្ទរកថារបស់ឯកឧត្តម HORINOUCHI Hidehisa ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីចុះហត្ថលេខាលើ លិខិតប្តូរសារស្តីពីការផ្តល់ជំនួយឥតសំណងរបស់ជប៉ុន

ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៧

- សូមគោរព ឯកឧត្តម **Prak Sokhonn** ទេសរដ្ឋមន្ត្រី
  រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- សូមគោរព ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស អស់លោក លោកស្រី

ថ្ងៃនេះខ្ញុំមានសេចក្តីសប្បាយរីករាយណាស់ដែលបានចុះហត្ថលេខាលើលិខិតប្តូរសារ និងកំណត់ហេតុនៃការពិភាក្សាសម្រាប់ជំនួយឥតសំណងរបស់ជប៉ុន។

ជាដំបូង ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **Prak Sokhnon** ហើយខ្ញុំក៏សូមអរគុណដល់មន្ត្រីពាក់ព័ន្ធទាំងអស់ដែលបានរៀបចំពិធីនាថ្ងៃនេះ។

ជំនួយឥតសំណងដែលបានចុះហត្ថលេខានាថ្ងៃនេះមានទឹកប្រាក់សរុប3,942លានយ៉េន ឬប្រមាណ35លានដុល្លារអាមេរិកសម្រាប់គម្រោងសាងសង់ស្ពានបន្ទាន់នៅតំបន់រងគ្រោះដោយសារទឹកជំនន់។

កម្ពុជាបានរងគ្រោះដោយទឹកជំនន់ដ៏ធ្ងន់ធ្ងរចំនួន2ដង ក្នុងឆ្នាំ2011 និង2013 ដែលធ្វើអោយប៉ះពាល់ដល់ប្រជាជនច្រើនជាង1លាន7សែននាក់ និងបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធអស់ជាច្រើនផងដែរ។ តាមរយៈ គម្រោងនេះ ស្ពានចំនួន2តាមបណ្តោយផ្លូវជាតិលេខ11ក្នុងខេត្តព្រៃវែង និងស្ពានចំនួន5តាមបណ្តោយផ្លូវជាតិលេខ73ក្នុងខេត្តក្រចេះ និងផ្លូវភ្ជាប់ស្ពាន នឹងត្រូវសាងសង់ឡើងវិញដើម្បីធានាបាននូវការដឹកជញ្ជូន និងlogistics ប្រកបដោយសុវត្ថិភាព រលូន និងស្ថិរភាព។

ផ្លូវជាតិលេខ11 មានតួនាទីសំខាន់ក្នុងតំបន់ ដោយភ្ជាប់ផ្លូវ Highway ជាច្រើន ដូចជា ផ្លូវជាតិលេខ1 លេខ7 និងលេខ8 ព្រមទាំងរួមចំណែកលើកកម្ពស់ពាណិជ្ជកម្មក្នុងតំបន់ផងដែរ។ ដូចគ្នានេះ ផ្លូវជាតិលេខ73ក៏មានសារៈសំខាន់ក្នុងការដឹកជញ្ជូនទំនិញទៅកាន់ខេត្តភាគឦសាននៃប្រទេសដែលមានអត្រាក្រីក្រខ្ពស់ជាងគេ។ ដូច្នេះ គម្រោងនេះបានរួមចំណែកក្នុងការអភិវឌ្ឍបណ្តាញផ្លូវ ដែលចាំបាច់ក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងរួមចំណែកក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិង សង្គមរបស់កម្ពុជា ព្រមទាំងពង្រឹងជាបន្តទៅទៀតនូវ ទំនាក់ទំនងមិត្តភាពរវាងជប៉ុននិងកម្ពុជា។

សូមអរគុណ!